# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ ៤៩ .សសរ**

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ /នស/រកម/៩៤ ចុះថ្ងៃទី២០ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០១ /នស/៩៤ ចុះថ្ងៃទី១៥ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលបានប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង
- យោងសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍

# សម្រេច

**ប្រការ១** : ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីគ្រប់គ្រង និងរៀបចំអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ អន្លង់វែង ដែលមានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **ថោង ខុន** | រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | ប្រធាន |
| ២- ឯកឧត្តម **រស់ រ៉េន** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- ឯកឧត្តម **ស្តើង សុខុម** | អនុរដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- ឯកឧត្តម **ហាប់ អូម៉ាលី** | អនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | អនុប្រធាន |
| ៥- ឯកឧត្តម **ហ៊ាន ម៉ុនធៀប** | អនុរដ្ឋលេខាធិការ ក្រសួងសាធារណៈការ និងដឹកជញ្ជូន | អនុប្រធាន |
| ៦- ឯកឧត្តម **ឡុង សារ៉ាឌុច** | អនុរដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម | អនុប្រធាន |
| ៧- ឯកឧត្តម **អ៊ុំ ម៉ែន** | អភិបាលរងខេត្តឧត្តរមានជ័យ | អនុប្រធាន |
| ៨- ឯកឧត្តម **ទិត ចន្ថា** | អគ្គនាយកទេសចរណ៍ ក្រសួងទេសចរណ៍ | សមាជិក |
| ៩- ឯកឧត្តម **ជា មូរ៉ា** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ | សមាជិក |
| ១០- ឯកឧត្តម **ឱក សុផុន** | អគ្គនាយកបច្ចេកទេស ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១១- លោក **ហេង្យ ម៉ុណ្ណារ៉ាក់** | អគ្គនាយករង ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២- លោក **ឡុត សារ៉ាឌុច** | អគ្គនាយករងកិច្ចការបច្ចេកទេស ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ១៣- លោក **កើត ពុទ្ធថេរី** | អគ្គនាយករងទេសចរណ៍ ក្រសួងទេសចរណ៍ | សមាជិក |
| ១៤- លោក **ផាន់ ណាឌី** | អគ្គនាយករងបេតិកភណ្ឌ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ១៥- លោក **យឹម ផាន់ណា** | អភិបាលស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ | សមាជិក |
| ១៦- លោក **ម៉ាន់ ថាន់** | នាយរងមជ្ឈមណ្ឌលឯកសារកម្ពុជា | សមាជិក |
| ១៧- លោក **អេង កុយឆាយ** | នាយរងមជ្ឈមណ្ឌលឯកសារកម្ពុជា | សមាជិក |
| ១៨- លោក **តួច វណ្ណៈ** | ប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន ក្រសួងទេសចរណ៍ | សមាជិក |
| ១៩- លោក **ផាន់ សារឿន** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ២០- លោក **ចាប់ សុវណ្ណា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ២១- លោក **សេក សុធីរិទ្ធ** | អនុប្រធាននាយកដ្ឋាននគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| ២២- លោក **គឹម ប៊ុណ្ណា** | អនុប្រធាននាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ២៣- លោកស្រី **ធិននី មុនីរស្មី** | ប្រធានមន្ទីរទេសចរណ៍ ខេត្តឧត្តរមានជ័យ | សមាជិក |

**ប្រការ២** : គណៈកម្មការអន្តរក្រសួងនេះត្រូវធ្វើការជម្រុញរៀបចំដឹកនាំគ្រប់គ្រង និងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រ អន្លង់វែងដើម្បីអនុវត្តអោយបានសម្រេចជោគជ័យ អនុក្រឹត្យលេខ៣៥អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០។ គណៈកម្មការនេះមានមុខងារ និងភារៈកិច្ចដូចតទៅ:

- រៀបចំគម្រោងប្លង់មេក្នុងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអោយមានរបៀបរៀបរយទៅតាមលំដាប់ថ្នាក់
- កោះអញ្ជើញសមាជិកគណៈកម្មការប្រជុំពិគ្រោះយោបល់លើគម្រោងអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង
- ចុះធ្វើការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រពិតនៅក្នុងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ដើម្បីរៀបចំចងក្រងជាឯកសារមគ្គុទ្ទេសក៍
- ប្រមូលគ្រប់ភស្តុតាងដែលនៅសល់យកមករក្សាទុក ដើម្បីរៀបចំធ្វើជាសារមន្ទីរហាលវាល
- ធ្វើការផ្សព្វផ្សាយដល់គ្រប់ភ្ញៀវទេសចរជាតិ និងអន្តរជាតិអោយបានទូលំទូលាយទាំងក្នុង និងក្រៅប្រទេស
- ធ្វើការផ្សព្វផ្សាយដល់គ្រប់ស្ថាប័ន អង្គការក្រៅរដ្ឋាភិបាល ដើម្បីស្វែងរកប្រភពទុនជួយឧបត្ថម្ភគាំទ្រលើគម្រោងផែនការអភិវឌ្ឍន៍
- លើកជាគម្រោងជូនរដ្ឋាភិបាល ដើម្បីធ្វើការសិក្សាបែងចែកអនុវត្តទៅតាមជំនាញ
- ធ្វើរបាយការណ៍អំពីលទ្ធផលជាប្រចាំជូនរាជរដ្ឋាភិបាល ។

**ប្រការ៣** : គណៈកម្មការអន្តរក្រសួងនេះមានលេខាធិការដ្ឋានមួយជាជំនួយការដែលមានទីតាំងនៅក្រសួងទេសចរណ៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ និងចំណាយថវិការបស់ក្រសួងទេសចរណ៍ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- លោក | **ភើត ពុទ្ធវី** | អគ្គនាយករងទេសចរណ៍ ក្រសួងទេសចរណ៍ | ប្រធាន |
| ២- លោក | **តួខ វណ្ណៈ** | ប្រធាននាយកដ្ឋានទេសចរណ៍វប្បធម៌ និងរមណីយដ្ឋាន ក្រសួងទេសចរណ៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោក | **សេក សុធីរិទ្ធ** | អនុប្រធាននាយកដ្ឋាននគរូបនីយកម្ម ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | អនុប្រធាន |
| ៤- លោក | **គីម ប៉ុណ្ណា** | អនុប្រធាននាយកដ្ឋានផ្លូវថ្នល់ ក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ៥- លោក | **ថាច់ សុវណ្ណា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រង និងអភិរក្សធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| ៦- លោក | **ឈឹម សុខជិន** | អនុប្រធាននាយកដ្ឋានអប់រំបណ្តុះបណ្តាល ក្រសួងទេសចរណ៍ | សមាជិក |
| ៧- លោក | **នូ សុផល** | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍ | សមាជិក |
| ៨- លោក | **ហោខ សុជានី** | អនុប្រធាននាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ | សមាជិក |
| ៩-លោក | **សុគន្ធ ណារ៉ុខ** | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ ក្រសួងទេសចរណ៍ | សមាជិក |

**ប្រការ៤** : គណៈកម្មការអន្តរក្រសួងនេះអាចរៀបចំបង្កើតក្រុមការងារបន្ថែមតាមការចាំបាច់ ដោយមានការយល់ព្រមពីប្រធានគណៈកម្មការ ។

**ប្រការ៥** : សមាជិកគណៈកម្មការទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងអាចប្រើប្រាស់មន្ត្រីក្នុងអង្គភាពរបស់ខ្លួនបន្ថែមទៅតាមសំណូមពរ និងទំហំការងារជាក់ស្តែង ។

**ប្រការ៦** : គណៈកម្មការអន្តរក្រសួងមានសិទ្ធិស្វែងរកដៃគូឯកជន ឬអង្គការក្រៅរដ្ឋាភិបាល ដើម្បីជួយទ្រទ្រង់ដល់ដំណើរការអភិវឌ្ឍតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ។

**ប្រការ៧** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សាលាខេត្តឧត្តរមានជ័យ សាលាស្រុកអន្លង់វែង មជ្ឈមណ្ឌលឯកសារកម្ពុជា ក្រសួង ស្ថាប័ន អាជ្ញាធរពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ និងប្រការ៣ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ៣ ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ